**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មការមូលបត្រកម្ពុជា**

លេខៈ.....០០៩/១០....គ.ម.ក/ប្រ.ក

# ប្រកាស

## ស្តីពី

## ការទទួលស្គាល់ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និង ភ្នាក់ងារទូទាត់

*****

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១០

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Temporary Address: # 99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia www.secc.gov.kh
Phone : 855-23-885-611 Fax . 855-23-885-622
E-mail : info@secc.gov kh

Downloaded from http://www.khmerlaws.com

# ស ម្រេ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.- គោលបំណង**

ប្រកាសនេះមានគោលបំណងកំណត់នូវលក្ខខណ្ឌតម្រូវ និងនីតិវិធីដើម្បីទទួលស្គាល់បុគ្គលធ្វើជាភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ជំនួស ព្រមទាំងកំណត់អំពីកាតព្វកិច្ចរបស់ភ្នាក់ងារនីមួយៗ ដោយអនុលោមតាមច្បាប់ស្តីពីការបោះ-ផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ប្រការ ២.- និយមន័យ**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងប្រកាសនេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

-ច្បាប់ (Law) សំដៅដល់ច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

-អនុក្រឹត្យ (Anukret) សំដៅដល់អនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

-ភ្នាក់ងារបញ្ជិកាមូលបត្រ (Securities Registrar) សំដៅដល់បុគ្គលដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ឱ្យផ្តល់សេវាក្នុងនាមក្រុមហ៊ុនបោះផ្សាយក្នុងក្របខណ្ឌនៃការបោះផ្សាយលក់មូលបត្រ ដូចខាងក្រោម ÷

ក-គ្រប់គ្រងឱ្យបានត្រឹមត្រូវនូវដំណើរការនៃការធ្វើបរិវិសកម្មនិងការបែងចែកមូលបត្រ (Securities Allotment) ស្របតាមនីតិវិធីបោះផ្សាយលក់មូលបត្រ។

ខ-កត់ត្រាបញ្ជីកម្មសិទ្ធិករមូលបត្រក្រោយពេលធ្វើការបែងចែកមូលបត្រត្រូវបានបញ្ចប់នៅទីផ្សារដំបូង ។

គ-ធ្វើរបាយការណ៍ស្តីពីការបញ្ចប់ និងជោគជ័យនៃការរក្សាទុកមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ ជូនក្រុមហ៊ុនបោះផ្សាយ និង **គ.ម.ក.** ។



Downloaded from http://www.khmerlaws.com

ឃ-ជូនដំណឹងដល់កម្មសិទ្ធិករមូលបត្រដោយបញ្ជាក់ពីភាពជាម្ចាស់លើមូល-បត្រដែលបានធ្វើបរិវិសកម្មមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយ។

ង-សេវាពាក់ព័ន្ធដទៃទៀតដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.**។

-ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ (Securities Transfer Agent) សំដៅដល់បុគ្គលដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ឱ្យផ្តល់សេវាក្នុងនាមក្រុមហ៊ុនបោះផ្សាយ ក្រោយពេលមូលបត្រត្រូវបានបែងចែកទៅឱ្យអ្នកធ្វើបរិវិសកម្ម ដូចខាងក្រោម ÷

ក-រក្សា និងគ្រប់គ្រងបញ្ជីកម្មសិទ្ធិករមូលបត្ររួមទាំងព័ត៌មានលំអិតរបស់កម្ម-សិទ្ធិករមូលបត្រឱ្យមានសង្គតិភាពជាមួយនឹងកំណត់ត្រារបស់ប្រតិបត្តិកររក្សាទុកមូលបត្រ។

ខ-រដ្ឋបាលកិច្ចពាក់ព័ន្ធនឹងការផ្លាស់ប្តូរកម្មសិទ្ធិ ការធ្វើរបាយការណ៍ ស្ថិតិ និងព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងសកម្មភាពរបស់ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

គ-រៀបចំការងារពាក់ព័ន្ធនឹងសិទ្ធិកម្មសិទ្ធិករមូលបត្រ ដែលត្រូវផ្តល់ដោយក្រុមហ៊ុនបោះផ្សាយ (Corporate actions) ដូចជាការជូនដំណឹងអំពីការបែងចែកភាគលាភការបង់ការប្រាក់ ជាដើម។

ឃ-បញ្ជូនរបាយការណ៍ និងព័ត៌មានផ្សេងៗរបស់ក្រុមហ៊ុនបោះផ្សាយទៅដល់កម្មសិទ្ធិករមូលបត្រ និងដោះស្រាយបញ្ហាទាក់ទងនឹងភាពជាម្ចាស់លើមូលបត្រពាក់ព័ន្ធនឹងសេវារបស់ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

ង-សេវាពាក់ព័ន្ធដទៃទៀតដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.**។

-ភ្នាក់ងារទូទាត់ ឬភ្នាក់ងារទូទាត់ជំនួស (Paying Agent) សំដៅដល់បុគ្គលដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ឱ្យផ្តល់សេវាក្នុងនាមក្រុមហ៊ុនបោះផ្សាយ ដូចខាងក្រោម ÷

ក-គណនាភាគលាភ ការប្រាក់ ប្រាក់ដើម ឬការទូទាត់ផ្សេងទៀតដែលត្រូវផ្តល់ឱ្យដល់កម្មសិទ្ធិករមូលបត្រ ឬភាគីពាក់ព័ន្ធ តាមការណែនាំរបស់ក្រុមហ៊ុនបោះផ្សាយ។

ខ-ធ្វើការទូទាត់ជូនកម្មសិទ្ធិករមូលបត្រ ឬភាគីពាក់ព័ន្ធក្នុងនាមក្រុមហ៊ុនបោះ-ផ្សាយ។

គ-បញ្ជូនព័ត៌មានចាំបាច់ដែលពាក់ព័ន្ធនឹងការទូទាត់ ឬព័ត៌មានផ្សេងទៀតដល់កម្មសិទ្ធិករមូលបត្រ និងរៀបចំរបាយការណ៍ពាក់ព័ន្ធនឹងការទូទាត់ទាំងនេះជូនទៅក្រុមហ៊ុនបោះផ្សាយ និង **គ.ម.ក.** តាមការចាំបាច់។



Downloaded from http://www.khmerlaws.com

ឃ-សេវាពាក់ព័ន្ធដទៃទៀតដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.**។

-បុគ្គលដាក់ពាក្យស្នើសុំ (Applicant) សំដៅដល់បុគ្គលដាក់ពាក្យស្នើសុំធ្វើជាភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់។

-បុគ្គលិកជាន់ខ្ពស់ (Senior staff) សំដៅដល់បុគ្គលិកដែលមានឋានៈចាប់ពីអគ្គនាយករហូតដល់នាយកឬប្រធានផ្នែក រួមទាំងលេខាធិការក្រុមហ៊ុន និងសវនករផ្ទៃក្នុង។

-អភិបាល (Director) សំដៅដល់ប្រធានក្រុមប្រឹក្សាភិបាល និងសមាជិកក្រុមប្រឹក្សាភិបាលរបស់បុគ្គលដាក់ពាកស្នើសុំ ឬរបស់ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់។

## ជំពូកទី ២
## លក្ខខណ្ឌនៃការទទួលស្គាល់

### ប្រការ ៣.-ការដាក់ពាក្យស្នើសុំ

បុគ្គលដែលមានបំណងធ្វើជាភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់ ត្រូវជាក្រុមហ៊ុនដែលចុះបញ្ជីពាណិជ្ជកម្មស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងត្រូវដាក់ពាក្យស្នើសុំដើម្បីបានការទទួលស្គាល់ពីអគ្គនាយកនៃ **គ.ម.ក.**។

### ប្រការ ៤.-បុគ្គលដាក់ពាក្យស្នើសុំ

បុគ្គលដាក់ពាក្យស្នើសុំធ្វើជាភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់អាចជា÷

១-ប្រតិបត្តិកររក្សាទុកមូលបត្រដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.**។

២-ធនាគារពាណិជ្ជដែលទទួលបានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា។

៣-ក្រុមហ៊ុនមូលធនផ្សេងទៀត ដូចមានចែងក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។

ក្នុងករណីបុគ្គលដាក់ពាក្យស្នើសុំធ្វើជាភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រដែលមិនមែនជាប្រតិបត្តិកររក្សាទុកមូលបត្រ បុគ្គលត្រូវមានកិច្ចសន្យាជាមួយប្រតិបត្តិកររក្សាទុកមូលបត្រស្តីពីការផ្តល់ព័ត៌មាននៃការផ្លាស់ប្តូរកំណត់ត្រាភាពជាម្ចាស់កម្មសិទ្ធិលើមូលបត្រ ដែលគ្រប់គ្រងដោយប្រតិបត្តិកររក្សាទុកមូលបត្រ។



Downloaded from http://www.khmerlaws.com

**ប្រការ ៥.- លក្ខខណ្ឌតម្រូវសម្រាប់បុគ្គលដាក់ពាក្យស្នើសុំ**

បុគ្គលដាក់ពាក្យស្នើសុំធ្វើជាភ្នាក់ងារបញ្ជិកាមូលបត្រ ឬភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់ជិន្ទូសត្រូវ ÷

១-មានដើមទុនអប្បបរមាជារូបិយវត្ថុជាតិចំនួន ÷

ក-២០០.០០០.០០០ (ពីររយលាន) រៀល ក្នុងករណីស្នើសុំធ្វើជាភ្នាក់ងារបញ្ជិកាមូលបត្រ។

ខ-២០០.០០០.០០០ (ពីររយលាន) រៀល ក្នុងករណីស្នើសុំធ្វើជាភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

គ-៥០០.០០០.០០០ (ប្រាំរយលាន) រៀល ក្នុងករណីស្នើសុំធ្វើជាភ្នាក់ងារទូទាត់។

២-ដាក់ប្រាក់តម្កល់ ១០ (ដប់) ភាគរយនៃដើមទុនអប្បបរមា នៅក្នុងគណនីរបស់ **គ.ម.ក.** នៅធនាគារជាតិនៃកម្ពុជា។ ក្នុងករណីចាំបាច់ ប្រាក់តម្កល់នេះ អាចដកយកមកប្រើប្រាស់បាន ដោយមានការអនុញ្ញាតជាមុនពី **គ.ម.ក.**។

៣-មានវិធានស្តីពីសេវា និងយន្តការក្នុងការផ្តល់សេវាដូចមានចែងក្នុងប្រការ ៩ នៃប្រកាសនេះ។

៤-មានប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ធ្វើប្រតិបត្តិការ និងប្រព័ន្ធទ្រទ្រង់ ដើម្បីធានាឱ្យបាននូវប្រតិបត្តិការប្រកបដោយសុវត្ថិភាព ប្រសិទ្ធភាព និងចីរភាព។

៥-មានអង្គភាពឬផ្នែកដាច់ដោយឡែក ដែលមានទ្រព្យនិងធនធានមនុស្សគ្រប់គ្រាន់ និងត្រូវបានគ្រប់គ្រងត្រឹមត្រូវសម្រាប់ផ្តល់សេវាជាភ្នាក់ងារបញ្ជិកាមូលបត្រ ឬភ្នាក់ងារចុះ-បញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់ ដើម្បីធានាបាននូវប្រសិទ្ធភាព គណនេយ្យភាព តម្លាភាព និងភាពទទួលខុសត្រូវ។ ករណីបុគ្គលដាក់ពាក្យស្នើសុំធ្វើជាភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ បុគ្គលនេះអាចមានរចនាសម្ព័ន្ធមួយសម្រាប់បំពេញសេវាភ្នាក់ងារទាំងបីនេះ នៅក្នុងអង្គភាពឬផ្នែកមួយដាច់ដោយឡែក។

៦-មានបុគ្គលដែលត្រូវតែងតាំងជាប្រធានផ្នែកប្រតិបត្តិការក្នុងការផ្តល់សេវាជាភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់ ដែលបំពេញលក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រការ ៨ នៃប្រកាសនេះ។



Downloaded from http://www.khmerlaws.com

ធនាគារពាណិជ្ជ ឬប្រតិបត្តិកររក្សាទុកមូលបត្រ អាចបង្កើតបុត្រសម្ព័ន្ធដើម្បីដាក់ពាក្យស្នើសុំធ្វើជាភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់។ ក្នុងករណីបុគ្គលដាក់ពាក្យស្នើសុំជាធនាគារពាណិជ្ជ ឬប្រតិបត្តិកររក្សាទុកមូលបត្រ លក្ខខណ្ឌតម្រូវស្តីពីដើមទុនអប្បបរមាដូចមានចែងក្នុងកថាខណ្ឌទី ១ ចំនុចទី ១ នៃប្រការនេះត្រូវបានលើកលែង។

ក្នុងករណីបុគ្គលដាក់ពាក្យស្នើសុំជាក្រុមហ៊ុនមូលធនផ្សេងទៀត ដែលកំពុងធ្វើសកម្មភាពធុរកិច្ច បុគ្គលដាក់ពាក្យស្នើសុំត្រូវបន្ថែមដើមទុនដូចមានចែងក្នុងកថាខណ្ឌទី ១ ក្នុងចំណុច ១ នៃប្រការនេះ លើដើមទុនបច្ចុប្បន្ន។

## ប្រការ ៦.– លក្ខណៈសម្បត្តិរបស់បុគ្គលដាក់ពាក្យស្នើសុំ

បុគ្គលដាក់ពាក្យស្នើសុំ បុគ្គលដែលត្រូវតែងតាំងជាអភិបាលនិងបុគ្គលិកជាន់ខ្ពស់របស់បុគ្គលដាក់ពាក្យស្នើសុំ ត្រូវគោរពតាមលក្ខខណ្ឌតម្រូវដូចខាងក្រោម ÷

១-មានលក្ខណសម្បត្តិនិងអត្តចរិតល្អ ដូចមានចែងក្នុងមាត្រា ៤២ នៃអនុក្រឹត្យ។

២-មិនធ្លាប់ត្រូវបានប្រកាសក្ស័យធន ឬមិនធ្លាប់បង្កឱ្យក្រុមហ៊ុនមួយឬច្រើនឈានទៅរកភាពក្ស័យធនក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំចុងក្រោយគិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំ។

៣-មិនធ្លាប់ប្រព្រឹត្តអំពើអ្វីដែលនាំឱ្យប៉ះពាល់ដល់ដំណើរការទីផ្សារមូលបត្រ ឬនៅក្នុងវិស័យហិរញ្ញវត្ថុ។

៤-មិនធ្លាប់ប្រព្រឹត្តអ្វីដែលប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ។

## ប្រការ ៧.– ឯកសារភ្ជាប់ជាមួយពាក្យស្នើសុំ

បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញបែបបទនៃពាក្យស្នើសុំ ទៅតាមទម្រង់ដែលបានកំណត់ដោយ **គ.ម.ក.** ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម ÷

១-វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

២-ប័ណ្ណប៉ាតង់ និង/ឬវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

៣-លក្ខន្តិកៈក្រុមហ៊ុនថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

៤-លិខិតបញ្ជាក់ពីដើមទុនអប្បបរមាដូចមានចែងក្នុងប្រការ ៥ នៃប្រកាសនេះ។

៥-រចនាសម្ព័ន្ធគ្រប់គ្រង មុខងារ និងការទទួលខុសត្រូវរបស់បុគ្គលិកនីមួយៗក្នុងរចនាសម្ព័ន្ធគ្រប់គ្រង។

៦-វិធានស្តីពីសេវា។



Downloaded from http://www.khmerlaws.com

៧-ផែនការអាជីវកម្មសម្រាប់រយៈពេលយ៉ាងតិច ០៣ (បី) ឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំ។

៨-ផែនការគ្រប់គ្រងហានិភ័យ។

៩-បញ្ជីរាយនាមក្រុមហ៊ុនបោះផ្សាយ ដែលបុគ្គលដាក់ពាក្យស្នើសុំធ្លាប់ផ្តល់ ឬមានបំណងផ្តល់សេវាភ្នាក់ងារបញ្ជិកាមូលបត្រ ឬសេវាកម្មភ្នាក់ងារផ្ទេរមូលបត្រ ឬសេវាភ្នាក់ងារទូទាត់។

**ប្រការ ៨.-គុណវុឌ្ឍិរបស់ប្រធានប្រតិបត្តិការ**

បុគ្គលដែលត្រូវតែងតាំងជាប្រធានប្រតិបត្តិការដូចមានចែងក្នុងប្រការ ៥ នៃប្រកាសនេះ ត្រូវមានចំណេះដឹង និងបទពិសោធន៍ពាក់ព័ន្ធនឹងអាជីវកម្មមូលបត្រ ឬវិស័យហិរញ្ញវត្ថុយ៉ាងតិច ០៣ (បី) ឆ្នាំ ដើម្បីដឹកនាំប្រតិបត្តិការរបស់ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់។

**ប្រការ ៩.-យន្តការនៃការផ្តល់សេវា**

វិធានស្តីពីសេវា និងយន្តការផ្តល់សេវារបស់ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់ ត្រូវបង្កើតឡើងដោយអនុលោមតាមជំពូកទី៣ នៃប្រកាសនេះ និងត្រូវទទួលបានការអនុញ្ញាតពី **គ.ម.ក.**។

រាល់សេវារបស់ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារ-ទូទាត់ ត្រូវធ្វើឡើងតាមរយៈកិច្ចសន្យាជាមួយក្រុមហ៊ុនបោះផ្សាយដែលជាអតិថិជន។

**ប្រការ ១០.-ឯកសារនិងការបំភ្លឺបន្ថែម**

អគ្គនាយកនៃ **គ.ម.ក.** អាចតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំផ្តល់ឯកសារ និងបំភ្លឺនូវចំណុច ឬព័ត៌មានផ្សេងទៀតតាមការចាំបាច់ ដើម្បីធានាថាបុគ្គលដាក់ពាក្យស្នើសុំបំពេញបានគ្រប់លក្ខខណ្ឌដែលមានចែងក្នុងប្រកាសនេះ។

**ប្រការ ១១.-ការបដិសេធពាក្យស្នើសុំ**

អគ្គនាយកនៃ **គ.ម.ក.** អាចបដិសេធលើពាក្យស្នើសុំការទទួលស្គាល់ដោយផ្អែកលើមូលហេតុដូចខាងក្រោម ៖



Downloaded from http://www.khmerlaws.com

១-បុគ្គលដាក់ពាក្យស្នើសុំមិនបានបំពេញនូវលក្ខខណ្ឌណាមួយ ដែលមានចែងក្នុងប្រកាសនេះ ឬសេចក្ដីណែនាំផ្សេងទៀតដែលធ្វើនៅក្រោមប្រកាសនេះ ឬបទប្បញ្ញត្តិជាធរមានដែលពាក់ព័ន្ធផ្សេងទៀត។

២-ព័ត៌មាន ឬឯកសារដែលបុគ្គលដាក់ពាក្យស្នើសុំបានដាក់ជូន **គ.ម.ក.** មានលក្ខណៈក្លែងបន្លំ ឬដែលនាំឱ្យយល់ខុស។

៣-បុគ្គលដាក់ពាក្យស្នើសុំស្ថិតក្នុងស្ថានភាពឈានទៅរកការបញ្ឈប់ ឬរំលាយអាជីវកម្ម។

៤-សេចក្ដីសម្រេចរបស់តុលាការ ដែលតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំ ទូទាត់សងបំណុល មិនត្រូវបានអនុវត្តទាំងស្រុង ឬមួយផ្នែកដោយបុគ្គលដាក់ពាក្យស្នើសុំនោះ។

៥-បុគ្គលដាក់ពាក្យស្នើសុំ ឬអភិបាល ឬបុគ្គលិកជាន់ខ្ពស់របស់បុគ្គលដាក់ពាក្យស្នើសុំ ÷

ក-បានធ្វើអាជីវកម្មដែលមានលក្ខណៈបោកបញ្ឆោត ឬកេងប្រវ័ញ្ច ឬមិនត្រឹមត្រូវដោយប្រការណាមួយ។

ខ-បានប្រព្រឹត្តល្មើសនឹងច្បាប់ ឬបទប្បញ្ញត្តិ ដែលការពារសាធារណជនឱ្យចៀសផុតពីការខាតបង់ផ្នែកហិរញ្ញវត្ថុ ដោយសារតែភាពមិនស្មោះត្រង់ អសមត្ថភាព ឬការប្រព្រឹត្តមិនត្រឹមត្រូវរបស់បុគ្គលនោះ ក្នុងការផ្ដល់សេវាហិរញ្ញវត្ថុ ឬក្នុងការគ្រប់គ្រងក្រុមហ៊ុន។

គ-បានធ្វើ ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយផ្សេងទៀត ដែលធ្វើឱ្យមានការសង្ស័យចំពោះសមត្ថភាព និងសុក្រឹតភាពនៃសេចក្ដីសម្រេចរបស់ខ្លួន។

ឃ-ស្តែងចេញនូវភាពមិនអាចធ្វើសកម្មភាព ដើម្បីផលប្រយោជន៍អតិថិជនរបស់ខ្លួន ដោយសារតែកេរ្តិ៍ឈ្មោះ បុគ្គលិកលក្ខណៈ សេចក្ដីសុចរិត និងភាពដែលអាចទុកចិត្តបានផ្នែកហិរញ្ញវត្ថុរបស់បុគ្គលទាំងនោះ។

ង-ស្តែងចេញនូវភាពមិនអាចធ្វើអាជីវកម្មបាន ក្រោមលក្ខខណ្ឌនៃការទទួលស្គាល់ប្រកបដោយប្រសិទ្ធភាព ភាពស្មោះត្រង់ និងយុត្តិធម៌។

៦-នៅពេលកើតមានហេតុការណ៍ណាមួយដែលអាច ÷

ក-នាំឱ្យបុគ្គលដាក់ពាក្យស្នើសុំ ឬអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំមិនអាចធ្វើអាជីវកម្មបានត្រឹមត្រូវ។



Downloaded from http://www.khmerlaws.com

៦-ឆ្លុះបញ្ចាំងពីភាពមិនអាចជឿជាក់បានលើវិធីធ្វើអាជីវកម្ម របស់បុគ្គលដាក់ពាក្យស្នើសុំ។

៧-បុគ្គលដាក់ពាក្យស្នើសុំមាន ឬអាចនឹងមានការពាក់ព័ន្ធនឹងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឬការទទួលស្គាល់បុគ្គលដាក់ពាក្យស្នើសុំអាចនឹងនាំឱ្យប៉ះពាល់ផលប្រយោជន៍សាធារណៈ។

អគ្គនាយកនៃ **គ.ម.ក.** មិនត្រូវបដិសេធការទទួលស្គាល់លើពាក្យស្នើសុំ ដោយមិនបានផ្តល់មូលហេតុជាលាយលក្ខណ៍អក្សរជាមុនឡើយ។

## ជំពូកទី ៣

## វិធានស្តីពីសេវា និងផែនការអាជីវកម្ម របស់ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់

### ប្រការ ១២.–វិធានស្តីពីសេវារបស់ភ្នាក់ងារបញ្ជិកាមូលបត្រ

វិធានស្តីពីសេវាភ្នាក់ងារបញ្ជិកាមូលបត្រ របស់បុគ្គលដាក់ពាក្យស្នើសុំធ្វើជាភ្នាក់-ងារបញ្ជិកាមូលបត្រដូចមានចែងក្នុងប្រការ ៥ នៃប្រកាសនេះ ត្រូវចែងពីនីតិវិធីទាក់ទងនឹងប្រតិបត្តិការសេវាកម្មរបស់ភ្នាក់ងារបញ្ជិកាមូលបត្រ។ វិធានស្តីពីសេវារបស់ភ្នាក់ងារបញ្ជិកាមូលបត្រត្រូវមានចែងជាអប្បបរមានូវ÷

១-វិសាលភាពនៃសកម្មភាពសេវា និងប្រភេទមូលបត្របោះផ្សាយដែលពាក់ព័ន្ធ។

២-លក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់ ព្យួរ និងបញ្ឈប់សេវា ចំពោះក្រុមហ៊ុនបោះ-ផ្សាយ និងភាគីពាក់ព័ន្ធដទៃទៀត។

៣-កម្រៃសេវានានាដែលកំណត់សម្រាប់ក្រុមហ៊ុនបោះផ្សាយ និងភាគីពាក់ព័ន្ធ។

៤-សិទ្ធិ និងកាតព្វកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយដែលជាអតិថិជន និងភាគីពាក់ព័ន្ធដទៃទៀតក្នុងការទទួលយកសេវាបញ្ជិកាមូលបត្រ។

៥-និទ្ទេសដែលតម្រូវឱ្យចែងនៅក្នុងកិច្ចព្រមព្រៀងសេវាបញ្ជិកាមូលបត្រ ដែលនឹងធ្វើជាមួយក្រុមហ៊ុនបោះផ្សាយមូលបត្រដែលជាអតិថិជន និងភាគីពាក់ព័ន្ធដទៃទៀត។

៦-វិធីសាស្ត្រស្តីពីការអនុវត្តនូវការបែងចែកមូលបត្រ ការកត់ត្រាបញ្ជិកានៃភាពជាម្ចាស់កម្មសិទ្ធិលើមូលបត្រក្រោយការធ្វើបរិវិសកម្ម។



Downloaded from http://www.khmerlaws.com

៧-នីតិវិធីស្ដីពីការជូនព័ត៌មានពីសេវានានា ដល់ក្រុមហ៊ុនបោះផ្សាយ កម្មសិទ្ធិករមូលបត្រ និងភាគីពាក់ព័ន្ធដទៃទៀត។

៨-នីតិវិធីសំរាប់គ្រប់គ្រងនូវរាល់អាកប្បកិរិយា ដែលត្រូវបានហាមឃាត់ទាក់ទិនទៅនឹងវិស័យមូលបត្រដូចដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ១៣.–វិធានស្ដីពីសេវារបស់ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ**

វិធានស្ដីពីសេវាភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ របស់បុគ្គលដាក់ពាក្យស្នើសុំធ្វើជាភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រដូចមានចែងក្នុងប្រការ ៥ នៃប្រកាសនេះ ត្រូវចែងពីនីតិវិធីទាក់ទងនឹងប្រតិបត្តិការសេវាកម្មរបស់ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។ វិធានស្ដីពីសេវារបស់ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រត្រូវមានចែងជាអប្បបរមានូវ ÷

១-វិសាលភាពនៃសកម្មភាពសេវា និងប្រភេទមូលបត្របោះផ្សាយដែលពាក់ព័ន្ធ។

២-លក្ខខណ្ឌ និងនីតិវិធីនៃការផ្ដល់ ព្យួរ និងបញ្ឈប់សេវា ចំពោះក្រុមហ៊ុនបោះផ្សាយ និងភាគីពាក់ព័ន្ធដទៃទៀត។

៣-កម្រៃសេវានានាដែលកំណត់សម្រាប់ក្រុមហ៊ុនបោះផ្សាយ កម្មសិទ្ធិករមូលបត្រ និងភាគីពាក់ព័ន្ធ។

៤-សិទ្ធិ និងកាតព្វកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយដែលជាអតិថិជន និងភាគីពាក់ព័ន្ធដទៃទៀត។

៥-និទ្ទេសដែលតម្រូវឱ្យចែងនៅក្នុងកិច្ចព្រមព្រៀងសេវាចុះបញ្ជីផ្ទេរមូលបត្រ ដែលនឹងធ្វើជាមួយក្រុមហ៊ុនបោះផ្សាយមូលបត្រដែលជាអតិថិជន និងភាគីពាក់ព័ន្ធដទៃទៀត។

៦-នីតិវិធីដើម្បីធានាបាននូវភាពត្រឹមត្រូវ ក្នុងការកត់ត្រាការចុះបញ្ជីផ្ទេរមូលបត្រនៃកម្មសិទ្ធិករមូលបត្រ របស់ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឱ្យស្របតាមកំណត់ត្រារបស់ប្រតិបត្តិកររក្សាទុកមូលបត្រ។

៧-នីតិវិធីក្នុងការគ្រប់គ្រងនូវការកត់ត្រាការចុះបញ្ជីផ្ទេរមូលបត្រ ដែលមិនបានចុះបញ្ជីផ្លូវការក្នុងទីផ្សារមូលបត្រប្រតិស្រុត។

៨-នីតិវិធីស្ដីពីការជូនព័ត៌មានពីសេវានានា ដល់ក្រុមហ៊ុនបោះផ្សាយ កម្មសិទ្ធិករមូលបត្រ និងភាគីពាក់ព័ន្ធដទៃទៀត។

៩-វិធាន **និងនីតិវិធី**សម្រាប់គ្រប់គ្រងនូវរាល់អាកប្បកិរិយា ដែលត្រូវ**បានហាមឃាត់**ទាក់ទិនទៅនឹងវិស័យមូលបត្រដូចដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។



Downloaded from http://www.khmerlaws.com

## ប្រការ ១៤.-វិធានស្តីពីសេវារបស់ភ្នាក់ងារទូទាត់

វិធានស្តីពីសេវាភ្នាក់ងារទូទាត់ របស់បុគ្គលដាក់ពាក្យស្នើសុំធ្វើជាភ្នាក់ងារទូទាត់ ដូចមានចែងក្នុងប្រការ ៥ នៃប្រកាសនេះ ត្រូវចែងពីនីតិវិធីទាក់ទងនឹងប្រតិបត្តិការសេវាកម្ម របស់ភ្នាក់ងារទូទាត់។ វិធានស្តីពីសេវាភ្នាក់ងារទូទាត់ត្រូវមានចែងជាអប្បបរមានូវ ៖

១-វិសាលភាពនៃសកម្មភាពសេវា និងប្រភេទមូលបត្របោះផ្សាយដែលពាក់ព័ន្ធ។

២-លក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់ ល្វូរ និងបញ្ឈប់សេវាកម្ម ចំពោះក្រុមហ៊ុនបោះផ្សាយ និងភាគីពាក់ព័ន្ធដទៃទៀត។

៣-កម្រៃសេវានានាដែលកំណត់សម្រាប់ក្រុមហ៊ុនបោះផ្សាយ កម្មសិទ្ធិករមូលបត្រនិងភាគីពាក់ព័ន្ធ។

៤-សិទ្ធិ និងកាតព្វកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយដែលជាអតិថិជន និងភាគីពាក់ព័ន្ធដទៃទៀត។

៥-និទ្ទេសដែលតម្រូវឱ្យចែងនៅក្នុងកិច្ចព្រមព្រៀងសេវាទូទាត់ ដែលនឹងធ្វើជាមួយក្រុមហ៊ុនបោះផ្សាយមូលបត្រដែលជាអតិថិជន និងភាគីពាក់ព័ន្ធដទៃទៀត។

៦-នីតិវិធីនៃការទូទាត់ភាគលាភ ការប្រាក់ និងប្រាក់ដើម និងការទូទាត់ផ្សេងទៀតដល់កម្មសិទ្ធិករមូលបត្រ និងភាគីពាក់ព័ន្ធ។

៧-នីតិវិធីស្តីពីការជូនព័ត៌មានពីសេវានានា ដល់ក្រុមហ៊ុនបោះផ្សាយ កម្មសិទ្ធិករមូលបត្រ និងភាគីពាក់ព័ន្ធដទៃទៀត។

៨-វិធាន និងនីតិវិធីសំរាប់គ្រប់គ្រងនូវរាល់អាកប្បកិរិយា ដែលត្រូវបានហាមឃាត់ទាក់ទិនទៅនឹងវិស័យមូលបត្រដូចដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ប្រការ ១៥.-ផែនការអាជីវកម្ម

ផែនការអាជីវកម្មរបស់បុគ្គលដាក់ពាក្យស្នើសុំ ដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ ត្រូវមានចែងលម្អិតជាអប្បបរមានូវ ៖

១-យុត្តិកម្មទៅតាមលក្ខណៈសេដ្ឋកិច្ច និងគម្រោងយុទ្ធសាស្ត្រទាក់ទងទៅនឹងការបង្កើតអាជីវកម្មដែលពិពណ៌នាអំពីសេវាដែលត្រូវធ្វើ។

២-ការកំណត់កម្រៃសេវា និងព្យាករណ៍ទាក់ទងនឹងប្រាក់ចំណូល។

៣-ហានិភ័យ និងផែនការយថាភាព (Contingency Plan) ដែលពាក់ព័ន្ធនឹងនិរន្តរភាពនៃប្រតិបត្តិការសេវា។

៤-ផែនការហិរញ្ញវត្ថុដែលត្រូវមានយ៉ាងហោចណាស់នូវ ៖

-ផែនការស្ថានភាពហិរញ្ញវត្ថុ (Pro Forma Balance Sheet)។



Downloaded from http://www.khmerlaws.com

-ផែនការលទ្ធផល (Pro Forma Income Statement)។

-ផែនការលំហូរសាច់ប្រាក់ (Pro Forma Statement of Cash flow)។

**ប្រការ ១៦.–ការបង្កើត ការកែប្រែ ឬលុបចោលវិធានស្តីពីសេវា**

ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់ មិនត្រូវបង្កើត កែប្រែ ឬលុបចោលវិធានស្តីពីសេវារបស់ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់ ដោយគ្មានការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.** ឡើយ។ អគ្គនាយកនៃ **គ.ម.ក.** អាចស្នើសុំជាលាយលក្ខណ៍អក្សរដល់ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់ ឱ្យបង្កើត កែប្រែ ឬលុបចោល វិធានផ្តល់សេវា ដោយកំណត់ពេលជាក់លាក់មួយ។ ក្នុងករណីភ្នាក់ងារមិនគោរពតាមការស្នើសុំរបស់ **គ.ម.ក.** ក្នុងអំឡុងពេលជាក់លាក់ដូចដែលបានកំណត់ នោះ **គ.ម.ក.** អាចរៀបចំបង្កើត កែប្រែ លុបចោលវិធាននានា ទៅតាមអ្វីដែល **គ.ម.ក.** បានដាក់ស្នើសុំឱ្យកែប្រែ។

## ជំពូកទី ៤
## ការទទួលស្គាល់ កម្រៃ និងបន្ទុក

**ប្រការ ១៧.–រយៈពេលនៃការសម្រេចផ្តល់ការទទួលស្គាល់**

បន្ទាប់ពីបុគ្គលដាក់ពាក្យស្នើសុំបានបំពេញតាមគ្រប់លក្ខខណ្ឌ ដែលមានចែងក្នុងបទប្បញ្ញត្តិជាធរមាន និងប្រកាសនេះ ក្នុងរយៈពេលយ៉ាងយូរ ០២ (ពីរ) ខែ អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងពីការទទួលស្គាល់ ឬជូនដំណឹងអំពីការបដិសេធដល់បុគ្គលដាក់ពាក្យស្នើសុំ។ ក្នុងករណីអគ្គនាយកនៃ **គ.ម.ក.** ស្នើសុំឱ្យបុគ្គលដាក់ពាក្យស្នើសុំ កែប្រែ ឬផ្តល់ព័ត៌មានបន្ថែមនោះ លក្ខខណ្ឌពេលវេលាក្នុងការពិនិត្យ និងសម្រេចត្រូវគិតសាឡើងវិញ ចាប់តាំងពីកាលបរិច្ឆេទដែលព័ត៌មានទាំងនោះត្រូវបានផ្តល់ជូនដល់ **គ.ម.ក.**។

**ប្រការ ១៨.–សុពលភាពនៃការទទួលស្គាល់**

សុពលភាពនៃការទទួលស្គាល់មានរយៈពេលមិនកំណត់។



Downloaded from http://www.khmerlaws.com

### ប្រការ ១៩.- កម្រៃនៃការទទួលស្គាល់ប្រចាំឆ្នាំ និងកម្រៃផ្សេងទៀត

បុគ្គលដាក់ពាក្យស្នើសុំ ត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតចំនួន ១.០០០.០០០ (មួយលាន) រៀល នៅពេលដាក់ពាក្យស្នើសុំធ្វើជាភ្នាក់ងារនីមួយៗ។ ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតនេះ មិនត្រូវបានប្រគល់ជូនបុគ្គលដាក់ពាក្យស្នើសុំវិញឡើយ ទោះបីជាមានការបដិសេធលើពាក្យស្នើសុំក៏ដោយ។

បុគ្គលដែលទទួលបានការទទួលស្គាល់ ត្រូវបង់ថ្លៃការទទួលស្គាល់ប្រចាំឆ្នាំដូចខាងក្រោម ÷

១-ភ្នាក់ងារបញ្ជិកាមូលបត្រត្រូវបង់ចំនួន ១.០០០.០០០ (មួយលាន) រៀល។

២-ភ្នាក់ងារផ្ទេរមូលបត្រត្រូវបង់ចំនួន ១.០០០.០០០ (មួយលាន) រៀល។

៣-ភ្នាក់ងារទូទាត់ត្រូវបង់ចំនួន ២.០០០.០០០ (ពីរលាន) រៀល។

សម្រាប់ឆ្នាំបន្តបន្ទាប់ ភ្នាក់ងារនីមួយៗ ត្រូវបង់ថ្លៃការទទួលស្គាល់ប្រចាំឆ្នាំយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃខែដែលទទួលបានការទទួលស្គាល់។

## ជំពូកទី ៥

## ភារកិច្ចរបស់ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់

### ប្រការ ២០.- ការចាប់ផ្តើមអាជីវកម្ម

បន្ទាប់ពីបានការទទួលស្គាល់ ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់ ត្រូវចាប់ផ្តើមសកម្មភាពអាជីវកម្មរបស់ខ្លួនក្នុងរយៈពេលយ៉ាងយូរ ០៣ (បី)ខែ ដោយគិតចាប់ពីថ្ងៃដែលភ្នាក់ងារបានទទួលការទទួលស្គាល់ពី **គ.ម.ក.** ឬរយៈពេលសមស្រប ដែលអនុញ្ញាតដោយអគ្គនាយកនៃ **គ.ម.ក.**។

### ប្រការ ២១.- ភារកិច្ចទូទៅ

ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់ត្រូវ ÷

១-ផ្តល់សេវារបស់ខ្លួនឱ្យដំណើរការប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

២-ត្រួតពិនិត្យ និងគ្រប់គ្រងដោយប្រុងប្រយ័ត្នខ្ពស់នូវរាល់ហានិភ័យ ដែលកើតឡើងពីអាជីវកម្ម ឬប្រតិបត្តិការណាមួយ។



Downloaded from http://www.khmerlaws.com

៣-បំពេញនូវរាល់កាតព្វកិច្ចដែលមានចែងនៅក្នុងប្រកាសនេះ និងបទប្បញ្ញត្តិជាធរមាន និងដោយមិនត្រូវប្រព្រឹត្តអ្វីដែលផ្ទុយពីផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍វិនិយោគិន។

៤-អនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានស្តីពីសេវារបស់ភ្នាក់ងារនីមួយៗ។

៥-ធ្វើការផ្សព្វផ្សាយជាសាធារណៈនូវឈ្មោះក្រុមហ៊ុនបោះផ្សាយ និងប្រភេទមូលបត្រ ដែលស្ថិតក្នុងការផ្តល់សេវារបស់ភ្នាក់ងារនីមួយៗ តាមទីតាំងរបស់ភ្នាក់ងារនីមួយៗ ដើម្បីឱ្យវិនិយោគិន ឬសាធារណជនអាចងាយមើលឃើញ។

## ប្រការ ២២.- ការធានារ៉ាប់រងវិជ្ជាជីវៈ

បុគ្គលដែលទទួលបានការទទួលស្គាល់ធ្វើជាភ្នាក់ងារទូទាត់ ត្រូវមានការធានារ៉ាប់រងវិជ្ជាជីវៈ មុនពេលចាប់ផ្តើមធ្វើប្រតិបត្តិការ។

## ប្រការ ២៣.- ការបញ្ចប់អាជីវកម្ម

ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់ ត្រូវស្នើសុំបញ្ចប់ប្រតិបត្តិការផ្តល់សេវាជាភ្នាក់ងារនីមួយៗ មក **គ.ម.ក.** ដោយភ្ជាប់មកជាមួយនូវនីតិវិធីបញ្ចប់សេវា ក្នុងពេលយ៉ាងតិច ០៦ (ប្រាំមួយ)ខែ មុនថ្ងៃបញ្ចប់សេវា។ ការបញ្ចប់ប្រតិបត្តិការសេវាកម្ម នីតិវិធី និងរយៈពេលបញ្ចប់សេវា ត្រូវទទួលការយល់ព្រមពី **គ.ម.ក.**។ ក្នុងករណីនីតិវិធីនៃការបញ្ចប់សេវារបស់ភ្នាក់ងារនីមួយៗ ប្រើប្រាស់ពេលលើសពី ០៦ (ប្រាំមួយ) ខែ **គ.ម.ក.** មានសិទ្ធិកំណត់រយៈពេលបន្ថែម។

ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ក្រុមហ៊ុនបោះផ្សាយ ស្តីពីការបញ្ចប់ប្រតិបត្តិការផ្តល់សេវាជាភ្នាក់ងារនីមួយៗ និងការផ្ទេរបញ្ជីមូលបត្រ និងឯកសារពាក់ព័ន្ធ ទៅឱ្យភ្នាក់ងារស្នងដែលទទួលបន្តផ្តល់សេវា ឬផ្ទេរត្រលប់ឱ្យទៅក្រុមហ៊ុនបោះផ្សាយដែលជាអតិថិជន បន្ទាប់ពីមានការយល់ព្រមពី **គ.ម.ក.**។

## ប្រការ ២៤.- ការផ្តល់របាយការណ៍របស់ភ្នាក់ងារបញ្ជិកាមូលបត្រ

ភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវផ្តល់ជូន **គ.ម.ក.** នូវរបាយការណ៍តាមប្រតិបត្តិការសេវាកម្មក្នុងការបោះផ្សាយលក់មូលបត្រម្តងៗ (Report by issue) ដែលត្រូវបង្ហាញនូវព័ត៌មានដូចខាងក្រោម ÷



Downloaded from http://www.khmerlaws.com

១-ឈ្មោះក្រុមហ៊ុនបោះផ្សាយ។

២-ប្រភេទមូលបត្រ។

៣-ចំនួនមូលបត្រ។

៤-ចំនួនកម្មសិទ្ធិករមូលបត្រ។

៥-ឈ្មោះភាគីពាក់ព័ន្ធនឹងដំណើរការបោះផ្សាយ។

៦-ព័ត៌មានចាំបាច់ដទៃទៀត។

**ប្រការ ២៥.–ការផ្តល់របាយការណ៍ប្រចាំត្រីមាសរបស់ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ**

ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ត្រូវផ្តល់ជូន **គ.ម.ក.** នូវរបាយការណ៍ប្រចាំត្រីមាស ដែលបង្ហាញពីព័ត៌មានដូចខាងក្រោម÷

១-ឈ្មោះក្រុមហ៊ុនបោះផ្សាយ។

២-ប្រភេទមូលបត្រ។

៣-ចំនួនមូលបត្រ។

៤-ចំនួនកម្មសិទ្ធិករមូលបត្រ។

៥-ភាគរយនៃភាពជាម្ចាស់កម្មសិទ្ធលើក្រុមហ៊ុនបោះផ្សាយរបស់កម្មសិទ្ធករមូលបត្រនីមួយៗ។

៦-ព័ត៌មានចាំបាច់ដទៃទៀត។

**ប្រការ ២៦.–ការផ្តល់របាយការណ៍ប្រចាំត្រីមាសរបស់ភ្នាក់ងារទូទាត់**

ភ្នាក់ងារទូទាត់ ត្រូវផ្តល់ជូន **គ.ម.ក.** នូវរបាយការណ៍ប្រចាំត្រីមាសដែលបង្ហាញពីព័ត៌មានដូចខាងក្រោម ÷

១-ឈ្មោះក្រុមហ៊ុនបោះផ្សាយលក់មូលបត្រដែលជាអតិថិជន។

២-ចំនួនកម្មសិទ្ធិករមូលបត្រ។

៣-ប្រភេទមូលបត្រ។

៤-ចំនួនមូលបត្រ។

៥-ទំហំនៃការទូទាត់ភាគលាភ ការប្រាក់ ប្រាក់ដើម និងការទូទាត់ផ្សេងទៀតទៅតាមក្រុមហ៊ុនបោះផ្សាយនីមួយៗ។

៦- ព័ត៌មានចាំបាច់ដទៃទៀត។



Downloaded from http://www.khmerlaws.com

ប្រការ ២៧.- ការផ្តល់របាយការណ៍ប្រចាំឆ្នាំ

ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់ ត្រូវផ្តល់របាយការណ៍អំពីសកម្មភាពប្រចាំឆ្នាំជូនមក **គ.ម.ក.** ក្នុងរយៈពេល ០៣(បី)ខែ បន្ទាប់ពីបញ្ចប់ឆ្នាំសារពើពន្ធ ឬបន្ទាប់ពីពេលវេលាណាមួយដែលអនុញ្ញាតដោយអគ្គនាយកនៃ **គ.ម.ក.**។

របាយការណ៍ស្តីពីសកម្មភាពប្រចាំឆ្នាំរបស់ភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវបង្ហាញយ៉ាងហោចណាស់អំពី÷

១-ឈ្មោះក្រុមហ៊ុនបោះផ្សាយ។

២-ចំនួនប្រតិបត្តិការសេវាកម្មបញ្ជិកាមូលបត្រ។

៣-ប្រភេទមូលបត្រ។

៤-ចំនួនមូលបត្រ។

៥-ចំនួនគណនីរបស់កម្មសិទ្ធិករមូលបត្រដែលស្ថិតនៅក្រោមការកត់ត្រា។

៦-តម្លៃចារឹក និងតម្លៃបរិវិសកម្មនៃមូលបត្រនីមួយៗ ដែលបានកត់ត្រា។

៧-ព័ត៌មានចាំបាច់ផ្សេងទៀត។

របាយការណ៍ប្រចាំឆ្នាំរបស់ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ត្រូវបង្ហាញយ៉ាងហោចណាស់អំពី÷

១-ឈ្មោះក្រុមហ៊ុនបោះផ្សាយ។

២-ចំនួនប្រតិបត្តិការចុះបញ្ជីផ្ទេរមូលបត្រ។

៣-ប្រភេទមូលបត្រ។

៤-ចំនួនមូលបត្រ។

៥-ភាគរយនៃភាពជាម្ចាស់កម្មសិទ្ធិលើក្រុមហ៊ុនបោះផ្សាយរបស់កម្មសិទ្ធិករមូលបត្រនីមួយៗ។

៦-ព័ត៌មានចាំបាច់ដទៃទៀត។

របាយការណ៍ប្រចាំឆ្នាំរបស់ភ្នាក់ងារទូទាត់ ត្រូវបង្ហាញយ៉ាងហោចណាស់អំពី÷

១-ឈ្មោះក្រុមហ៊ុនបោះផ្សាយ។

២-ចំនួនកម្មសិទ្ធិករមូលបត្រ។

៣-ប្រភេទមូលបត្រ។



Downloaded from http://www.khmerlaws.com

៤-ចំនួនមូលបត្រ។

៥-ទំហំនៃការទូទាត់ភាគលាភ ការប្រាក់ ប្រាក់ដើម និងការទូទាត់ផ្សេងទៀតទៅតាមក្រុមហ៊ុនបោះផ្សាយនីមួយៗ។

៦- ព័ត៌មានចាំបាច់ដទៃទៀត។

**ប្រការ ២៨.-ការត្រួតពិនិត្យដោយ គ.ម.ក.**

ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់ អាចត្រូវបានត្រួតពិនិត្យដែលធ្វើឡើងដោយ **គ.ម.ក.** លើស្ថានភាព និងប្រសិទ្ធភាពនៃប្រតិបត្តិការសេវាកម្មរបស់ភ្នាក់ងារនីមួយៗ។

ភ្នាក់ងារនីមួយៗត្រូវផ្តល់កិច្ចសហការល្អដល់មន្ត្រីត្រួតពិនិត្យរបស់ **គ.ម.ក.** ក្នុងគោលដៅធានានូវប្រសិទ្ធភាពការងារ។

**ប្រការ ២៩.-ការគោរពលក្ខខណ្ឌនៃប្រកាស**

បន្ទាប់ពីទទួលបានការទទួលស្គាល់ ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់ ត្រូវគោរពតាមលក្ខខណ្ឌដូចដែលមានចែងក្នុងប្រកាសនេះ។

## ជំពូកទី ៦

## ទោសប្បញ្ញត្តិ

**ប្រការ ៣០.-ទណ្ឌកម្មរដ្ឋបាល**

អគ្គនាយកនៃ **គ.ម.ក.** មានសិទ្ធិដឹកនាំកែតម្រង់ ដាក់លក្ខខណ្ឌ ដាក់កំហិតបន្ថែម ឬព្យួរការទទួលស្គាល់ ក្នុងករណីដែលភ្នាក់ងារ ÷

១-ល្មើសនឹងលក្ខខណ្ឌនៃការទទួលស្គាល់។

២-ល្មើសនឹងកាតព្វកិច្ចដែលចែងក្នុងប្រកាសនេះ។

៣-មិនធ្វើតាមការណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.** ក្នុងការកែតម្រង់ផ្សេងៗ។

៤-មិនអាចអនុវត្តសេចក្តីសម្រេចរបស់តុលាការ ដែលតម្រូវឱ្យសងបំណុលមួយភាគ ឬទាំងស្រុង។

៥-កំពុងស្ថិតនៅក្នុងស្ថានភាពបច្ចេកទេស និង/ឬហិរញ្ញវត្ថុទន់ខ្សោយ។



Downloaded from http://www.khmerlaws.com

### ប្រការ ៣១.- ការដកហូតការទទួលស្គាល់

អគ្គនាយកនៃ **គ.ម.ក.** មានសិទ្ធិដកហូតការទទួលស្គាល់ ក្នុងករណីដែលភ្នាក់ងារ ÷

១-ទទួលបានការទទួលស្គាល់ដោយមធ្យោបាយក្លែងបន្លំណាមួយ។

២-នៅតែបន្តប្រតិបត្តិការក្នុងអំឡុងពេលព្យួរការទទួលស្គាល់។

៣-ផ្អាក ឬបញ្ឈប់ប្រតិបត្តិការ ដោយមិនទទួលបានការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.**។

៤-កំពុងត្រូវរំលាយដោយគ្មានលទ្ធភាពធ្វើអាជីវកម្មបន្ត ឬដោយការវិនិច្ឆ័យរបស់តុលាការ។

៥-មិនគោរពតាមការចាត់វិធានការដូចមានចែងក្នុងប្រការ ៣០ នៃប្រកាសនេះ។

### ប្រការ ៣២.- វិធានការពិន័យអន្តរការណ៍

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិក្នុងវិស័យមូលបត្រ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ភ្នាក់ងារនីមួយៗដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ ត្រូវទទួលការផាកពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ដល់ ២០.០០០.០០០ (ម្ភៃលាន) រៀល។ ដោយឡែកចំពោះការយឺតយ៉ាវក្នុងការបង់កម្រៃនៃការទទួលស្គាល់ដូចមានចែងក្នុងប្រការ ១៩ នៃប្រកាសនេះ ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់ ត្រូវទទួលការផាកពិន័យអន្តរការណ៍ជាប្រាក់ចំនួន ១០០.០០០(ដប់ម៉ឺន) រៀល ក្នុង ១ (មួយ) ថ្ងៃ ។

## ជំពូកទី ៧
## អន្តរប្បញ្ញត្តិ

### ប្រការ ៣៣.- លក្ខខណ្ឌលើកលែងជាបណ្តោះអាសន្ន

ករណីដែលប្រតិបត្តិកររក្សាទុកមូលបត្រមិនទាន់ធ្វើប្រតិបត្តិការ លក្ខខណ្ឌនៃការទទួលស្គាល់ភ្នាក់ងារដូចមានចែងក្នុងកថាខ័ណ្ឌទី ២ ប្រការ ៤ នៃប្រកាសនេះត្រូវបានលើកលែងជាបណ្តោះអាសន្ន។



Downloaded from http://www.khmerlaws.com

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**ប្រការ ៣៤.- គោលការណ៍ណែនាំផ្សេងៗ**

**គ.ម.ក.** អាចចេញគោលការណ៍ណែនាំ ដើម្បីសម្រួលការយល់ដឹងនិងការអនុវត្ត តាមលក្ខខណ្ឌនៃប្រកាសនេះ ដល់បុគ្គលពាក់ព័ន្ធ អ្នកចូលរួមក្នុងទីផ្សារមូលបត្រ និងដល់សាធារណជន។

**ប្រការ ៣៥.- បដិទានកម្ម**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៣៦.- ការអនុវត្ត**

អគ្គនាយក អគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០១០

**គាត ឈន់**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- គណៈកម្មការមូលបត្រកម្ពុជា
- គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣៦ "ដើម្បីអនុវត្ត"
- អគ្គនាយកដ្ឋានរាជកិច្ច
- ឯកសារ-កាលប្បវត្តិ



Downloaded from http://www.khmerlaws.com